**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

* * * *

ភាគី "ក" ខ្ញុំបាទឈ្មោះ Wanlop Longrarerng អាយុ៣៧ឆ្នាំ ភេទប្រុស សញ្ជាតិថៃ តំណាងអោយ ក្រុមហ៊ុន **អង្គរ ហ្សីបឡាញ ឯ.ក** មានអាសយដ្ឋាន៖ ផ្ទះលេខ A៧៣ វិថីCharles de Gaulle តំបន់ទេសចរណ៍ បុរីប្រឹមប្រិយ ភូមិត្រពាំងសេះ សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប។

និង

ភាគី "ខ" ខ្ញុំបាទឈ្មោះ យុត ខេមរិន អាយុ ២៦ឆ្នាំ ភេទប្រុស សញ្ជាតិខ្មែរ តំណាងអោយ បុគ្គលិកបំរើការទាំងអស់ អោយក្រុមហ៊ុន **អង្គរ ហ្សីបឡាញ ឯ.ក** មានអាសយដ្ឋាន៖ នៅភូមិគោកថ្មី ឃុំពួក ស្រុកពួក ខេត្តសៀមរាប។

**បានឯកភាពគ្នាដូចខាងក្រោម**

ដោយសារបញ្ហានៃការរីករាតត្បាតនៃជម្ងឺកូវីដ-១៩(Covid-19) ដែលបានធ្វើឱ្យប៉ះពាល់ដល់វិស័យជាច្រើន ជាពិសេសវិស័យទេសចរណ៍ ដែលជាហេតុធ្វើឱ្យចំនួនភ្ញៀវទេសចរដែលចូលមកតំបន់ទេសចរណ៍នានាក្នុងខេត្តសៀមរាប រួមទាំងរមនីយដ្ឋានសៀមរាបអង្គរ មានការធ្លាក់ចុះយ៉ាងខ្លាំង។ ប្រការនេះបានជះឥទ្ធិពលយ៉ាងខ្លាំងដល់ប្រតិបត្តិការអាជីវកម្មរបស់ក្រុមហ៊ុនយើងខ្ញុំ ដែលពឹងផ្អែកទាំងស្រុងទៅលើភ្ញៀវទេសចរ ជាពិសេសភ្ញៀវទេសចរអន្តរជាតិ។

យោងទៅតាមហេតុផលខាងលើ យើងខ្ញុំជានិយោជក និង និយោជិតបានឯកភាព សម្រេចផ្អាក អាជីវកម្មកន្ត្រកយោងខ្សែកាប ជាបណ្តោះអាសន្នរហូតដល់ស្ថានភាពនៃការរីករាតត្បាតនៃជម្ងឺកូវីដ-១៩ (Covid-19) បានប្រសើរឡើង ហើយមានការអនុញ្ញាតឱ្យមានការធ្វើដំណើរកំសាន្តជាធម្មតា ទាំងក្នុង និងក្រៅប្រទេស។

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
ធ្វើនៅសៀមរាប, ចុះថ្ងៃទី ០៧ ខែឧសភា ឆ្នាំ២០២០

ភាគី "ក"
លោក LONGRARERNG WANLOP

ភាគី "ខ"
លោក យុត ខេមរិន